អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# ល្បែង៖ បាល់បោះស្រាបព្រា

**កម្មវិធីសិក្សា៖**

**ចិត្តចលភាព៖** បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**សិក្សាសង្គម៖** គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្ប:តាមរយៈការបង្កើតរូបភាព៖

**រយៈពេល៖** ៣០ នាទី

**ឧបករណ៍៖** ក្រដាសកេះ ក្រដាសជូតមាត់ប្រភេទណាក៏បានដែរ ឬកូនបាល់ជ័រ ស្លាបព្រាជ័រ កែវជ័រឬដបទឹកសិទ្ធ ការ ឬការទាន កន្ត្រៃ ទុយោរ ចង្កឹះ ។

**គោលបំណង៖**

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។ បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(សិក្សាសង្គម)**៖ ប្រាប់បានពីការបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់… និងបង្កើតរូបភាពផ្សេងៗ។

**ត្រៀម៖** ធ្វើសម្ភារ១ឬ២ឈុតសម្រាប់បង្ហាញកុមារមុនពេលដែលត្រូវលេងល្បែងសកម្មភាពមួយនេះ។

**សេចក្តីណែនាំ៖**

១. ប្រាប់កុមារថាថ្ងៃនេះពួកគេនឹងលេងល្បែងសកម្មភាពមួយដែលមានឈ្មោះថា ល្បែងបាល់បោះស្លាបព្រា។

២. បង្ហាញកុមារពីសម្ភារ ដែលសម្រាប់លេងល្បែងសកម្មភាពនេះជាមុនសិន។ ប្រាប់ថា នេះគឺជាសម្ភារដែលយកមកលេងល្បែងនេះ កូនៗចង់ធ្វើវាដែរឬទេ? កូនៗស្គាល់ល្បែងនេះដែរឬទេ? ធ្លាប់លេងវាពីមុនមកដែរឬទេ?

៣. ប្រាប់ពីការធ្វើសម្ភារលេងល្បែងនេះទៅកាន់កុមារ ប្រសិនបើពួកគេចង់ចេះ

- ក្រដាសកេះ ក្រដាសជូតមាត់ប្រភេទណាក៏បានដែរ ឬកូនបាល់ជ័រ ស្លាបព្រាជ័រ កែវជ័រឬដបទឹកសុទ្ធ ការ ឬការទាន ។

- បង្ហាញប្រាប់ពីការធ្វើឱ្យដូចជារូបនៅក្នុងរូបនេះ។

៤. ឱ្យកុមារលេងម្នាក់ម្តងៗ ដោយដាក់កូនបាល់លើផ្លែស្លាបព្រា ហើយយកដៃសង្កត់ផ្នែកខាងចុងនៃដងស្លាបព្រា រួចប្រលែងវា ឱ្យបាល់ហោះទៅលើ ដើម្បីចូលទៅក្នុងទីដែលបានដាក់ ឱ្យដូចជាការលេងបាល់បោះអញ្ចឹង។

៥. ឬយើងអាចលេងជាការប្រកួតគ្នាក៏បានដែរ ដោយឱ្យក្មេងៗលេងវាម្នាក់ម្តងៗ កុមារដែលធ្វើចូល ត្រូវឈរនៅកន្លែងអ្នកធ្វើចូល និងអ្នកមិនចូលឈរនៅមួយកន្លែងមិនចូល។

៦. បន្ទាប់មកឱ្យកុមារដែលធ្វើចូលទាំងអស់មកប្រកួតជាមួយគ្នាម្តងទៀត រហូតដល់អស់កុមារប្រសិនបើមានពេល។

៧. ធ្វើបែបហ្នឹងរហូតរកឃើញអ្នកឈ្នះបានជាការស្រេច។